ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៥៦.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី ២១ ខែ កញ្ញា ឆ្នាំ ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និង ប្រព្រឹត្តិទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

បង្កើត «គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ» ហៅកាត់ «គកហស» ដែលមានភារកិច្ចដឹកនាំរៀបចំ សម្របសម្រួលការអនុវត្ត និង តាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងមានភារកិច្ចសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ ។

**ប្រការ ២.-**

«គកហស» មានសមាសភាពដូចខាងក្រោម ÷

www.pheakdeylaw.com

១- រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា អនុប្រធាន

៣- អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការនៃគណៈកម្មាធិការនីតិសម្បទា និង អភិវឌ្ឍន៍កម្ពុជា អនុប្រធាន

៤- អគ្គលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធានប្រចាំការ

៥- តំណាងរបស់គ្រប់ក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល ថ្នាក់អគ្គលេខាធិការ ឬអគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ សមាជិក ។

**ប្រការ ៣.-**

«គកហស» មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយរបស់ខ្លួន នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ជាជំនួយការនៅក្នុងការបំពេញការងារ ។ លេខាធិការដ្ឋាននេះ ត្រូវបង្កើតដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមសំណើរបស់ប្រធាន «គកហស» ។

**ប្រការ ៤.-**

ដើម្បីធានាប្រសិទ្ធភាពនៃការរៀបចំ ការសម្របសម្រួលអនុវត្ត និង ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃបេសកកម្ម និងភារកិច្ចរបស់ «គកហស» ដូចមានចែងក្នុងប្រការ ១ ខាងលើ គ្រប់ក្រសួង-ស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត **«ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** មួយ នៅក្នុងក្រសួង-ស្ថាប័នរបស់ខ្លួន ។ ក្រុមការងារនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់មន្ត្រីតំណាងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាសមាជិកនៅក្នុង «គកហស» ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញសេចក្តីណែនាំស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមការងារនេះ ជូនដល់គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមសំណើរបស់ «គកហស» ។ ដោយឡែក ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវបង្កើត **«គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ»** មួយ ដែលត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធាន «គកហស» ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត និង ការតាមដានត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួង ។

www.pheakdeylaw.com

**ប្រការ ៥.-**

- «គមាស» មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង- ស្ថាប័នពាក់ព័ន្ធមកចូលរួមប្រជុំ ក្នុងករណីចាំបាច់
- «គមាស» មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និង តំណាងសង្គមស៊ីវិល ឱ្យចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬជាអ្នកសង្កេតការណ៍ ស្របទៅតាមតម្រូវការចាំបាច់នៃការងារ ។

**ប្រការ ៦.-**

- «គមាស» ធ្វើការតាមការអញ្ជើញរបស់ប្រធាន
- «គមាស» ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និង គ្រប់ប្រធានស្ថាប័នដែលមានការពាក់ព័ន្ធ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨ «ដើម្បីអនុវត្ត»
- ឯកសារ- កាលប្បវត្តិ

www.pheakdeylaw.com